**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងការពារជាតិ**

# សាររំលែកទុក្ខ

## ផ្ញើជូន

## លោកស្រី ឆែម កល្យាណា ព្រមទាំងក្រុមគ្រួសារ

**លោកស្រី ជាទីរាប់អាន !**

ក្នុងនាមក្រសួងការពារជាតិ និងក្នុងនាមខ្លួនខ្ញុំផ្ទាល់ ខ្ញុំមានក្ដីរំជួលចិត្តឥតឧបមាដោយបានទទួលដំណឹងអំពីមរណភាពរបស់**អនុសេនីយ៍ឯក ខេន ឆៃយុទ្ធ** អាកាសយានិកកងហោះទី២ **ផ្នែកហោះហើរ កងហោះឧទ្ធម្ភាគចក្រ បញ្ជាការដ្ឋានកងទ័ពជើងអាកាស** ដែលបានពលីដោយជួបឧបទ្ទវហេតុធ្លាក់ឧទ្ធម្ភាគចក្រក្នុងអំឡុងពេលបំពេញបេសកកម្មហោះហើរហ្វឹកហ្វឺន កាលពីថ្ងៃសុក្រ ៧កើត ខែអាសាឍ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨ ត្រូវនឹងថ្ងៃទី១២ ខែកក្កដា ឆ្នាំ២០២៤។

ក្នុងឱកាសប្រកបដោយសមានទុក្ខនេះ ខ្ញុំសូមសម្ដែងនូវការសោកស្ដាយ ស្រណោះអាឡោះអាល័យជាទីបំផុតជាមួយក្រុមគ្រួសារ**អនុសេនីយ៍ឯក ខេន ឆៃយុទ្ធ** ព្រោះការបាត់បង់នេះ គឺជាការបាត់បង់នាយទាហានអាកាសយានិកដ៏ឆ្នើមមួយរូប ដែលបានធ្វើពលិកម្មដើម្បីបុព្វហេតុជាតិមាតុភូមិជាទីស្នេហា និងរួមសុខទុក្ខជាមួយប្រជាជនកម្ពុជារហូតដល់ថ្ងៃអវសាននៃជីវិត។

ក្នុងនាមក្រសួងការពារជាតិ និងក្នុងនាមខ្លួនខ្ញុំផ្ទាល់ ខ្ញុំសូមឧទ្ទិសបួងសួងដល់ដួងវិញ្ញាណក្ខន្ធ**អនុសេនីយ៍ឯក ខេន ឆៃយុទ្ធ** សូមឆាប់បានចាប់កំណើតក្នុងសុគតិភពគ្រប់ៗជាតិកុំបីឃ្លៀងឃ្លាតឡើយ។

សូម **លោកស្រី ព្រមទាំងក្រុមគ្រួសារ** ទទួលនូវការរំលែកទុក្ខដ៏ក្រៀមក្រំពីខ្ញុំ។

ថ្ងៃអង្គារ ១០រោច ខែអាសាឍ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨

រាជធានីភ្នំពេញ ថ្ងៃទី៣០ ខែកក្កដា ឆ្នាំ២០២៤

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ**

**នាយឧត្តមសេនីយ៍ ទៀ សីហា**